**Declassified to Public**
**06 September 2012**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Chambres Extraordinaires au sein
des Tribunaux Cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**
**សំណុំរឿងព្រហ្មទណ្ឌ**
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**
**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 001/18-07-2007**

# កំណត់ហេតុនៃការសួរចម្លើយ
# Written Record of Interview of Charged Person
# Procès-verbal d'interrogatoire

ឆ្នាំពីរពាន់ប្រាំពីរ ខែសីហា ថ្ងៃទីម្ភៃបី នៅវេលាម៉ោងប្រាំបួននិងប្រាំមួយនាទី

យើង **យូ ប៊ុនឡេង** និង Marcel Lemonde ជាសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញ

ដោយមានលោក ហម ហ៊ើល និង លោក លី ច័ន្ទតុលា ជាក្រឡាបញ្ជីអមផង

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤

បានឃើញវិធាន ៥៨ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

ដោយមានវត្តមានរបស់ អ៊ួច ចាន់ណូរ៉ា និង យក់ ប៊ុនណា ជាអ្នកបកប្រែនៃអង្គជំនុំជម្រះវិសាមញ្ញដែលបានស្បថរួចហើយ។

ជនត្រូវចោទដែលមានអត្តសញ្ញាណដូចខាងក្រោម បានចូលខ្លួននៅចំពោះមុខយើង:
ឈ្មោះកាំង ហ្កេកអ៊ាវ ហៅ ឌុច ភេទ ប្រុស កើតថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ១៩៤២ នៅ ភូមិពៅវើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ សញ្ជាតិ ខ្មែរ របររកស៊ី គ្រូបង្រៀន។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

ឪពុកឈ្មោះ កាំង គី (ស្លាប់) ម្តាយឈ្មោះ មាស គីមសៀវ (រស់) ប្រពន្ធឈ្មោះ ឈឹម សុផល (ស្លាប់) មានកូន ០៤ នាក់ ទីលំនៅនៅភូមិអូរទទឹម ឃុំតាសាញ ស្រុកសំឡូត ខេត្តបាត់ដំបង។

ត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទល្មើសដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៥ មាត្រា ២៩ (ថ្មី) និង មាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

ច្បាប់ដើមនៃកំណត់ហេតុនេះ ត្រូវបានសរសេរជាភាសាខ្មែរ។

សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញ លោកRobert Petit និង អ្នកស្រី ជា លាង ដែលត្រូវបានជូនដំណឹងត្រឹមត្រូវរួចហើយអំពីការសួរចម្លើយនេះ នៅក្នុងកំណត់ហេតុសួរចម្លើយចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០០៧ ៖

☒ អ្នកស្រី ជា លាង មានវត្តមាន។

☒ លោក Robert Petit ត្រូវបានតំណាងដោយលោក Alex Bates, ជំនួយការជាន់ខ្ពស់របស់សហព្រះរាជអាជ្ញា។

លោកមេធាវី **ការ សាវុត្ថ** និង Francois Roux សហមេធាវីរបស់ជនត្រូវចោទត្រូវបានកោះអញ្ជើញ នៅក្នុងកំណត់ហេតុសួរចម្លើយចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០០៧ និង មានលទ្ធភាពបានពិនិត្យសំណុំរឿង តាំងពីពេលនោះមក មានវត្តមានទាំងពីរនាក់។

**ការសួរចម្លើយ**

**សួរ-ឆ្លើយ:**

សំនួររបស់ YBL: នៅដើមខែមករា ១៩៧៩ តើ អ្នកចេញពីស២១នៅពេលណា ? តើឯកសារនិងមនុស្ស ចាត់ចែងយ៉ាងណាមុនចាកចេញ ?

ឆ្លើយ: ខ្ញុំសុំនិយាយ។ នៅថ្ងៃ ៧មករា វេលាម៉ោង១១ កម្លាំងរថក្រោះកងទ័ពប្រឆាំង បានបើកមកដល់ផ្ទះខ្ញុំ។ ពេលនោះបុគ្គលិក ស២១ទាំងអស់ ស្រលាំងកាំង។ ពីព្រោះ វាផ្ទុយនឹងសេចក្តីណែនាំនិងបទបញ្ជាថ្ងៃ ៦ មករា ១៩៧៩។



Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

សំនួររបស់ ML : សេចក្តីណែនាំនោះ នរណាគេជាអ្នកចេញ និង មានន័យយ៉ាងម៉េច ?

ឆ្លើយ: បទបញ្ជាថា យើងអាចទប់ទល់សភាពការណ៍យោធាបាន។ ដូច្នោះ សុំតាំងស្មារតីនឹងនរ កុំភ្ញាក់ផ្អើល។

សំនួររបស់ML: តើនរណាគេនិយាយ?

ឆ ខៀវសំផន

សំនួររបស់ YBL: ថាខៀវសំផន និយាយអញ្ចឹង តើធ្វើនៅទីណា តើនរណាគេចូលរួម ?

សំនួរ ML តើលោកអាចបញ្ជាក់អំពីទំនាក់ទំនងរវាងលោក និង ខៀវសំផនបានទេ?

ឆ តាមការចាត់តាំង ខ្ញុំមិនមានទំនាក់ទំនងនឹងខៀវសំផនទេ។ នៅម៉ោង ៩ ថ្ងៃ ៦ ខែមករា មិត្តលីន បានទូរស័ព្ទមកហៅខ្ញុំទៅធ្វើការ។ ទទួលទូរស័ព្ទភ្លាម ខ្ញុំគិតថានួនជាអ្នកឱគេហៅខ្ញុំទៅធ្វើការ។ ខ្ញុំជិះម៉ូតូដល់ Lycee សុរាមរិត។ ខ្ញុំបានឃើញខៀវសំផន ហើយ មិនហ៊ានចូលទេ។ មិត្តលីន តឿនខ្ញុំបីដង និងយកដៃរុញស្មាខ្ញុំ។ ខ្ញុំក៏ចូលទៅអង្គុយកៅអីទំនេរមួយទល់មុខខៀវសំផន។ មុនចូលទៅ មានមនុស្ស បី បួន នាក់អង្គុយរួចហើយ ខ្ញុំស្គាល់តែមួយនាក់ទេ គឺ មិត្ត រឿង ដែលទទួលបន្ទុកឃ្លាំងរដ្ឋ។ ពេលខ្ញុំចូល ខៀវសំផន មិនហៅឈ្មោះខ្ញុំមួយម៉ាត់សោះ។ គាត់និយាយពីស្ថានការដូចដែលខ្ញុំបាននិយាយរួចមកហើយ។ ខ្ញុំឆ្ងល់ថាហេតុអីបានជាខៀវ សំផនទៅវិញ។

សំនួររបស់ ML: តើ លោកធ្លាប់បានជួបជាមួយខៀវសំផនទេពីមុនមក ?

ឆ្លើយ: ទេ។ ខ្ញុំ ជួបគាត់តែមួយដងគត់។ ខ្ញុំមិនអស់ចិត្តនឹងការជួបជាមួយខៀវសំផនពិតមែន បានន័យថា ព្រោះខ្ញុំមិនមានសិទ្ធិទៅជួបគាត់ទេ ហើយគាត់ក៏មិនមានសិទ្ធិជួបខ្ញុំដែរ។ ហេតុអី ក៏គាត់មក។ ប៉ុន្តែ ខ្ញុំទទួលយកការណែនាំរបស់គាត់ទៅផ្សព្វផ្សាយបន្តនៅស២១។ វាមិនមែនជាការជួបក្រៅផ្លូវការទេ។ ពិតជាមានការខន្ទេសនាមពីនួនជា។ នៅឆ្នាំ ១៩៨៣ នួនជា ចុះទៅគ្រប់គ្រងមុខសញ្ញាសំឡូត ហើយ ខ្ញុំនៅសំឡូត។ គាត់ (នួនជា) ហៅខ្ញុំទៅជួបសំណេះសំណាល។ ខ្ញុំ សុំនិយាយសំដីរបស់នួនជាដែលខ្ញុំនៅចាំស្ទើតែទាំងអស់។នួនជានិយាយថា នៅថ្ងៃ ៦ មករានោះ មិត្តធ្វើការជាមួយខៀវសំផន មិនធ្វើការជាមួយខ្ញុំទេ។ ដែលខ្ញុំយកខ្លឹមសារខៀវសំផននេះទៅផ្សព្វផ្សាយ គឺដោយសារ ខ្ញុំគិតថាមិត្តលីនមិនហ៊ានធ្វើអ្វីផ្តេះផ្តាស់ទេ។

សំនួររបស់ YBL : មុនជួបខៀវសំផន អ្នកជួបមនុស្សតែបីនាក់ទេនាកន្លែងនោះ ហើយ ស្គាល់តែរឿងទេ តើពីពេលនោះដល់អីឡូវ ដឹងថារឿងនោះ នៅរស់ទេ?

ឆ្លើយ: គាត់ស្លាប់ហើយ។

សំនួររបស់YBL : តើបន្ទាប់ពីការផ្សព្វផ្សាយព័តមាន តើឯកសារ និង អ្នកទោសចាត់ចែងដោយរបៀបម៉េច ?

ឆ ដំបូងសុំនិយាយអំពីជនរងគ្រោះដែលជាប់ឃុំឃាំងនៅ ស២១។ នៅថ្ងៃ ២ ឬ បី មករា ១៩៧៩ (ខ្ញុំចាំមិនច្បាស់ទេ) នួនជា ហៅខ្ញុំទៅទទួលបញ្ជាដាច់ខាតមួយ។ គឺតម្រូវឱ្យស២១ កំទេច (សម្លាប់) ជនរងគ្រោះឲអស់។ ចំពោះបញ្ជានេះ ខ្ញុំតក់ស្លុតណាស់។ ខ្ញុំយកបទបញ្ជានេះទៅប្រាប់មិត្ត ហ៊ី។

សំនួររបស់ YBL តើ ប្រាប់ ឬ បញ្ជា?

ឆ្លើយ:ប្រាប់។ ក្រោយពីប្រាប់ ហ៊ី រួចហើយ ដោយអស់សង្ឃឹមនឹងជីវិតស្រោប់ ខ្ញុំគិតតែពីដេក។ ខ្ញុំសុំបញ្ជាក់ឲច្បាស់។ មុនទទួលបញ្ជា ខ្ញុំជាមនុស្សអស់សង្ឃឹម៕

សំនួររបស់ML: ហេតុអី?

ឆ្លើយ:មានមូលហេតុពីរ។ ទី១ រហូតមកដល់ពេលនេះ គណ:បក្សកុំមុយនីស្តកម្ពុជាហាក់ដូចជាឆ្កួតវង្វេង ខ្ញុំមិនដឹងថារកពាក្យណាដាក់ឲត្រូវទេ។ អ្នកណាក៏បក្សចាត់ទុកថាជាខ្មាំង។ អ្នកណា ក៏ត្រូវចាប់បញ្ជូនមក ស២១ ដែរ។

សំនួររបស់ ML: អញ្ចឹង គ្រប់គ្នាគឺជាសត្រូវ ?

ឆ្លើយ: បាទ។ និងទី២ អ្វីដែលសង្កត់លើអារម្មណ៍ខ្ញុំខ្លាំង គឺមានការចាប់ខ្លួន និង សម្លាប់អនិកជនចិន ៤ នាក់ ដែលសុទ្ធតែជាអ្នកបំរើបក្សកុំមុយនីសយ៉ាងប្តូរផ្តាច់។ ទី១ ឈ្មោះ ថាក់ ។ ទី២ ស្វ ជា។ ទី៣ ស្វ យក់។ ទី៤ បង ង៉ែត យូ ហៅ ហុង។ មូលហេតុទី១ មានលក្ខណ: សត្យានុម័ត និង ទី២ អត្តនោមត្ត៕ ទាក់ទងនឹងចំនុចទី២នេះ ស្វ ជា ជាអ្នករកស៊ីចិញ្ចឹមបក្សកុំមុយនីសរាប់ឆ្នាំមកហើយ។ ប្រហែលជានៅឆ្នាំ ១៩៦៨ បក្ស បានផ្ញើរសារសម្ងាត់មួយតាមរយ:គាត់ទៅក្រសួងការបរទេសចិន។ នៅក្នុងសេចក្តីសារភាពរបស់គាត់ មានបញ្ជាក់ចំនុចនេះ។ សុំនិយាយតទៅទៀតទាក់បង ង៉ែត យូ។ គាត់ជាអ្នកការពារសុវត្ថភាព នួនជា ពេលនួនជាបង្កប់ខ្លួននៅភ្នំពេញ។ សំខាន់មែនទែនគឺ គាត់នឹងអ្នើយ។ គាត់បានរៀបចំឲប៉ុលពត អៀងសារី សុនសេន ភៀសខ្លួនទៅតំបន់រំដោះនៅវៀតណាម។ គាត់ជួលឡាន កាំម្នុងមួយ។ ផ្នែកខាងមុខដាក់ទំនិញ ចន្លោះកណ្តាល ដាក់កន្ទេលឲបីនាក់នោះអង្គុយ និង ខាងចុងដាក់ទំនិញ។

សំនួរ ML : តើនៅពេលណា?

ឆ. នៅដើមឆ្នាំ ១៩៦៤។

សំនួរ ML តើ ការអស់សង្ឃឹមរបស់លោក មានផលវិបាកអ្វីខ្លះ ?

ឆ. ដោយសាឃើញគុណបំណាច់ពីដំបូងរបស់ពួកគេដល់បក្សកុមមុយនីស្ត ដែលនួនជាក៏ទទួលស្គាល់ដែរ ហើយ បើប្រៀបធៀបរវាងការជួយរបស់ខ្ញុំនិងអ្នកទាំងពីរនាក់ ខ្ញុំមិនបានមួយចំណិតគេផង។ ខ្ញុំ គិតថាថ្ងៃណាមួយ



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

គង់គេចាប់ខ្ញុំយកទៅកាត់កដូចគេដែរ។ ខ្ញុំលាក់អារម្មណ៍នេះ មិនឲនរណាគេដឹងទេ តែសេចក្តីអស់សង្ឃឹមនេះ ត្រូវបង្ហាញចេញ ដោយសារខ្ញុំទៅអង្គុយសង្កុកនៅកន្លែងគូរ និង ឆ្លាក់ និង លែងធ្វើការងាររបស់ខ្ញុំ។

សំនួរ YBL តើអ្នកគូរ អ្នកឆ្លាក់ យកមកពីណា និង ឈ្មោះអីខ្លះ?

ឆ អ្នកគូរ ឈ្មោះ ម៉េង ខ្ញុំមិនច្បាស់ថាជាឈ្មោះពិត ឬ មិនទេ។ ទីពីរ អ្នកឆ្លាក់ ខ្ញុំមិនស្គាល់ឈ្មោះកំណើតគាត់ទេ តែជិតស្និតខ្ញុំហៅ អាឆ្លាក់។ ទីបី ឈ្មោះ ណាត ដែលខ្ញុំឲគាត់ជួយឆ្លាក់អាឆ្លាក់។ ខ្ញុំ មិនស្គាល់ត្រកូលទេ។ ណាត មិនមានជំនាញគូរទេ តែអាឆ្លាក់ មានបរិញ្ញាប័ត្រខាងឆ្លាក់។ ម៉េង រកស៊ីគូររូបឲរោងកុន។

សំនួរ YBL អ្នកទាំងបី ជាកម្មាភិបាល ឬ ជាជនរងគ្រោះ?

ឆ ជាជនរងគ្រោះ។

សំនួរ YBL តើបញ្ជូនជាឲកំទេច នៅថ្ងៃ ២ ឬ ៣ ខែ មករា មានអ្នករងគ្រោះប៉ុន្មាននាក់ដែលគេឃុំខ្លួន និង វិធីកំទេចរបៀបម៉េច?

ឆ. ចំនួនអ្នករងគ្រោះ ពិតប្រាកដ ខ្ញុំមិនចាំទេ។ និយាយឲចំ គឺ ខ្ញុំមិនយកចិត្តទុកដាក់លើចំនុចនោះទេ។ ខ្ញុំចាំថាអ្នករងគ្រោះ មាន២ជំពូក។ ទី១ ខ្មែរ ទី២ ទាហានវៀតណាមដែលលើកដៃចុះចូលនៅទួលស្លែង។

សំនួរ ML តើពួកគេជាអ្នកទោសសង្គ្រាម?

ឆ បាទ។

សំនួរ ML តើប្រហែលជាប៉ុន្មាន ១០០ ឬ ១០០០នាក់ ?

ឆ ទាំងអស់ប្រហែល២០០នាក់។

សំនួរ ML តើគេសម្លាប់ទាំងអស់ឬ?

ឆ ខ្ញុំជឿថាពួកគេត្រូវបានសម្លាប់ទាំងអស់។

សំនួរ ML តើលោកសម្លាប់គេដោយខ្លួនឯងឬ?

ឆ អត់ទេ។

សំនួរ YBL តើ២០០នាក់នេះ ជាចំនួនអ្នកទោសសរុបនៅស២១ ?

ឆ បាទ។

សំនួរ YBL តើ ក្នុងចំណោម ២០០នោះ តើ ទាហានវៀតណាមប៉ុន្មាននាក់?

ឆ ខ្ញុំសុំបញ្ជាក់។ ភារកិច្ចឃុំឃាំងនិងកំទេច ជាបន្ទុករបស់មិត្ត ហ៊ី តាំងពីពេលកកើតស២១មកម្លេះ។

សំនួរ ML មានន័យថាម៉េច ?

ឆ ពីមុនប្រធានគឺ ណាត។ ហើយ ណាត ចាត់តាំង ហ៊ី ឲទទួលការងារផ្នែកយោធាផ្ទាល់មុខ។ ការងារយោធានៅស២១ មានន័យថា ទី១ ទទួលជនរងគ្រោះដែលគេបញ្ជូនមក ទី២ ឃុំឃាំងជនរងគ្រោះនៅក្នុងពន្ធនាគារ ទី៣



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

នាំជនរងគ្រោះទៅកំទេច ទី៤ ការពារអន្តរាគមន៍ពីខាងក្រៅ។ ដល់ក្រោយមក ខ្ញុំឡើងជាប្រធាន ខ្ញុំមានភារកិច្ចត្រួតពិនិត្យនិងណែនាំ ប៉ុន្តែ ខ្ញុំមិនធ្វើការងារនេះទេ។

សំនួរ ML លោកកំពុងនិយាយថាលោកជាប្រធានដែលមិនមានអំណាច ប៉ុន្តែមានមនុស្សច្រើនដែលនិយាយថាលោកជាអ្នកសម្រេចគ្រប់អ្វីៗទាំងអស់?

ឆ រឿងទាំងអស់ដែលខ្ញុំរាយការណ៍សុទ្ធតែស្របតាមសភាពការណ៍ជាក់ស្តែង។ ខ្ញុំសុំជូនភស្តុតាងមួយដែលអាចនៅសល់នៅស២១។ ដំបូង ការនាំមនុស្សចេញទៅកំទេច គឺមិត្តហ៊ីជាអ្នកសម្រេចដោយមិនចាំបាច់ប្រាប់ខ្ញុំទេ។ ថ្ងៃមួយស្រាប់តែមេខ្ញុំ សុនសេន សួរខ្ញុំតាមទូរស័ព្ទថាហេតុម៉េចបានជាដាច់ចម្លើយរបស់ សឹង សានី ហៅ ប្រេវ បាត់មិនឃើញបន្តទៀត? ខ្ញុំឆ្លើយថា មិត្ត ប៉ុនកំពុងតែសួរ ស្រាប់តែមិត្តហ៊ីបាននាំយកទៅកម្ទេចបាត់ទៅដោយមិនដឹងថាគេកំពុងតែសួរ។ ដល់អញ្ចឹង លោកគ្រូស៊ុនសេន ប្រាប់ខ្ញុំឱប្រាប់មិត្តហ៊ី ថាចាប់តាំងពីពេលនេះទៅកុំឱសម្រេចតែឯកឯងយកជនរងគ្រោះចេញ។ និង ណែនាំឱហ៊ី សួរយោបល់ខ្ញុំសិនមុននឹងយកទៅ។ របស់ដែលនៅសល់នៅស២១ ទុកជាពន្លឺសម្រាប់បញ្ជាក់បញ្ហានេះ គឺ ទី១ ចម្លើយរបស់ សឹនសានី ដាច់មួយកំណាត់ ទី២ បញ្ជីឈ្មោះដែលមិត្តហ៊ីយកមកសុំអនុញ្ញាតពីខ្ញុំ និងមានចុះហត្ថលេខាខ្ញុំ អាចនឹងនៅសល់នៅស២១។

សំនួរ ML អនុញ្ញាតអំពីអ្វី?

ឆ ខ្ញុំនឹងពន្យល់។ពាក្យអនុញ្ញាតអាចប្រើមិនចំន័យចំពោះស្ថានការណ៍នោះ។ មុនរាល់ការសម្លាប់ ខ្ញុំត្រូវបញ្ជាក់ឱច្បាស់ថាការសួរចម្លើយត្រូវបានធ្វើចប់សព្វគ្រប់ហើយទាក់ទងនឹងបញ្ជីដែលហ៊ីបង្ហាញមកឱខ្ញុំ។ ដើម្បីឱច្បាស់ ទី១ការនាំមនុស្សទៅជើងឯក ជាការងាររបស់ហ៊ី។ ក្រោយមកដោយដាច់ចម្លើយមួយកំណាត់ ទើបសុនសេន ណែនាំឱហ៊ីសុំយោបល់ខ្ញុំសិនមុននឹងនាំជនរងគ្រោះទៅ។ គឺ ដើម្បីចៀសវាងកុំឱដាច់ចម្លើយដូចមុនទៀតតែប៉ុណ្ណោះ។ ដូច្នេះ រឿងនេះ មានតមកដល់ក្រោយទៀត តែមានការប្រែប្រួលបន្តិច។ នៅពេលដែលខ្ញុំអស់សង្ឃឹមនេះ ខ្ញុំមានបញ្ចេញប្រតិកម្មមួយទៀត។ គឺខ្ញុំសុំប្រគល់ការងារនៅភ្នំពេញនេះទៅឱ ហ៊ី គិតទាំងការការពារនិងសួរចម្លើយ។ នួនជា យល់ស្របនឹងការដែលឱហ៊ីក្តាប់ការងារនៅភ្នំពេញទាំងមូល។ ខ្ញុំទទួលខុសត្រូវរួមផ្នែកនយោបាយ ទាំងភ្នំពេញ និង ព្រៃស។

សំនួរ ML បានន័យថា គឺហ៊ីជាអ្នកទទួលខុសត្រូវពិតប្រាកដនៅភ្នំពេញ?

ឆ បាទ។

សំនួរ ML តែអ្នកផ្សេង មើលឃើញថាលោកជាអ្នកទទួលខុសត្រូវទៅវិញទេ?

ឆ រឿងនេះ វាស្ថិតនៅក្នុងការយល់មិនជិតដល់។ ប៉ុន្តែ បើមើលឱជ្រៅទៅ នឹងអាចឃើញថាវាជាការពិត។ សុំបន្តរឿងចាត់តាំង។ ក្រោយពីនួនជា យល់ស្របតាមសំណូមពររបស់ខ្ញុំឱចាត់តាំង ហ៊ី ប្រហែលជា២ ឬ ៣ ខែមក



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

នួនជា ប្រាប់ខ្ញុំថាប្រធាននៃស២១ មិនមែនខ្ញុំ ឌុច ទេ គឺ គាត់ នួនជា ជាប្រធាន។ ខ្ញុំយកពាក្យនេះមកផ្សព្វផ្សាយគ្រប់។

សំនួរ YBL ទាក់ទងនឹងមនុស្ស ២០០នាក់នោះ តើគេកំទេចដោយរបៀបម៉េច?

ឆ ទាក់ទងរឿងនេះ ខ្ញុំអត់ដឹងទេ។

សំនួរ YBL អត់ដឹងអីតិចតួចសោះតែម្តង?

ឆ អត់ដឹងទេ។ សុំបញ្ជាក់បន្ត។ ក្រោយពីយកបញ្ជានួនជាមកប្រាប់ ហ៊ី ខ្ញុំដេកទាំងថ្ងៃទាំងយប់ដោយក្តីអស់សង្ឃឹម។ តាំងពីពេលនោះមក គ្មាននរណាដែលឃើញខ្ញុំនៅកន្លែងគួរឆ្លាក់ទៀតទេ។ ឯណាក៏ខ្ញុំមិនទៅដែរ ទៅតែផ្ទះបាយប៉ុណ្ណោះ។ នេះ ជាហេតុការដែលបញ្ជាក់សកម្មភាពខ្ញុំនាថ្ងៃចុងក្រោយ។ ដំបូង ខ្ញុំ អាចទៅកន្លែងឆ្លាក់ដើម្បីបន្ធូរទុក្ខ។ តាំងពីបានទទួលបញ្ជានួនជា ខ្ញុំ លែងចេញក្រៅហើយ។

សំនួរ ML ជាសរុបទៅ លោកជាប្រធានដែលមិនមានអំណាច និង មិនដែលសម្រេចដោយខ្លួនឯងទេ ហើយមានតួនាទីត្រឹមតែបញ្ជូនបញ្ជា និង ចុងក្រោយ (នាចុងឆ្នាំ ១៩៧៨ ដល់ ១៩៧៩) លោកលែងដឹងអំពីអ្វីដែលកើតនៅស២១ គ្មាននរណាជូនដំណឹងលោកអំពីអ្វីដែលកើតឡើងនៅស២១ ទេ ?

ឆ អំណាចរបស់ខ្ញុំ គឺនាំពាក្យពីខាងលើមកផ្សព្វផ្សាយ ដោយមិនឲលើស មិនឲខ្វះ។ បង្កើតស២១ ដំបូងភារកិច្ចរបស់ខ្ញុំគឺអានសេចក្តីសារភាព និង រាយការណ៍ទៅសុនសេនតាមទូរស័ព្ទរាល់ថ្ងៃ។ អត់ពីសុនសេនទៅខ្ញុំយកមកប្រាប់នួនជា ៣ ឬ ៤ ឬ យ៉ាងយូរ ៥ ថ្ងៃម្តង ។ ឯអំណាចខ្ញុំ គឺនាំពាក្យថ្នាក់លើមកផ្សព្វផ្សាយទៅថ្នាក់ក្រោម និង រាយការណ៍អំពីចម្លើយសារភាពទៅថ្នាក់លើ។ សេចក្តីកត់សម្គាល់របស់លោក Marcel Lemonde មិនខុសទេ។ នួនជា បាននិយាយថាខ្ញុំក្តាប់ការងារមិនបាន។ ហើយនេះ ក៏ជាហេតុផលដែលបញ្ជាក់ថាខ្ញុំអស់សង្ឃឹម និង អត់ធ្វើអីមែន។ ដូច្នេះ ខ្ញុំជាប្រធានទ្រឹស្តី Chef theorique ប៉ុណ្ណោះ៕ ខ្ញុំសង្ឃឹមថាការស្រាវជ្រាវរបស់តុលាការនឹងឃើញការពិតនេះ។

សំនួរ ML យើងនឹងឃើញ។ ដោយគិតអំពីបរិបទនៃដំណើរការរបស់បក្សនាពេលនោះ តើលោកគិតថាបក្សអាចរក្សាទុកមនុស្សដែលអត់មានធ្វើអីដែរឬទេ?

ឆ ខ្ញុំសុំរំលឹកថាកាលពីលើកមុនលោកចៅក្រមបានសួរខ្ញុំថាហេតុអីបានជាគេតែងតាំងខ្ញុំឲធ្វើជាប្រធាន។ ខ្ញុំបានឆ្លើយនាពេលនោះថា ខ្ញុំមិនដឹងអីអំពីការតែងតាំងនោះទេ។ នេះជាចម្លើយដែលឈរលើហេតុការណ៍ជាក់ស្តែង។ នៅមានចម្លើយមួយទៀតដែលខ្ញុំមិនទាន់ហ៊ានជំរាបជូននាពេលនោះ គឺហេតុផលដែលឈរលើការវិភាគរបស់ខ្ញុំ។ ការវិភាគនេះ វាវែង តែបើលោកចៅក្រមអនុញ្ញាត ខ្ញុំសុំជម្រាប។

ឆ ទី១ ខ្ញុំសុំនិយាយអំពីមតិរបស់ វន វ៉េត ក្រោយដែលគេចាប់គាត់។ គាត់ថា ‶ បងប៉ុលនេះ ជាមនុស្សដែលយកជើងទ្រមេឃ ″(នេះជាពាក្យបុរាណកម្ពុជា)។ ដោយឃើញខ្ញុំ (វនវ៉េត) កាន់ក្រសួងឧស្សាហកម្មដែលមាន



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

មនុស្សរាប់ម៉ឺននាក់ បង ប៉ុល ចាប់ផ្តើមសង្ស័យខ្ញុំ។ ខ្ញុំ (ឌុច) បានគិត ២-៣ ថ្ងៃមុននឹងយកមតិនេះទៅប្រាប់នួនជា ដើម្បីចង់ដឹងប្រតិកម្មរបស់គាត់។ នួន ជាឆ្លើយផ្លូងថា វននវេតវាធ្វើអីកើត ព្រោះ ក្នុងអង្គភាពមួយៗមានគេមានឯង។ មតិនេះ ខ្ញុំជឿថាពិតទាំងពីរ។ ដូច្នេះ គេយកខ្ញុំមកដាក់ពីលើ ៧០៣ នៅស២១នេះ ដើម្បីឲខ្ញុំជាភ្នែកជាច្រមុះគេ។ បើកាលណា ៧០៣ ចាប់អាវុធផ្ទុះកណ្តាលទីក្រុងវិញ តើគេអាម៉ាស់ប៉ុណ្ណា? តាមពិតនៅក្នុងស២១ មានតែ ៧០៣ទេ ដែលមានលទ្ធភាពចាប់អាវុធ។ ឯចំណែក ម១៣ចាស់ មានយុទ្ធជនមិនដល់១០នាក់ផង និង មិនធ្លាប់ប្រយុទ្ធ។ ដូច្នេះ មិនមានលទ្ធភាពផ្ទុះអាវុធទេ។ នេះ ជាការវិភាគរបស់ខ្ញុំ។ ត្រូវប៉ុន្មានភាគរយ សុំតុលាការវិនិច្ឆ័យចុះ។

ផ្អាកការធ្វើកំណត់ហេតុនៃការសួរចម្លើយ នៅវេលាម៉ោងមួយសាមសិបប្រាំនាទី ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

នៅវេលាម៉ោងពីរ សែសិបប្រាំនាទីនៃថ្ងៃដដែល យើងចាប់ផ្តើមបន្តការសួរចម្លើយតទៅទៀត។

សំនួរ YBL និង ML: ពីព្រឹកម៉ិញ យើងបានសួរសំនួរទាក់ទងនឹងការចេញពីភ្នំពេញនាថ្ងៃ៧ មករា ទាក់ទងនឹងការចាត់ចែងមនុស្សជាអ្នកទោស។ អីឡូវ យើងចង់ដឹងអំពីការគ្រប់គ្រងឯកសារនាពេលនោះម្តង។ និយាយម្យាងទៀត ហេតុអីបានជាឯកសារនោះ ត្រូវទុកចោលនៅទីនោះ? តើមានការស្តីបន្ទោសលោកដែរឬទេទាក់ទងនឹងបញ្ហានេះ?

ឆ ខ្ញុំសុំនិយាយលំអិតដូចតទៅ។ សេចក្តីសារភាព ត្រូវធ្វើជា២ច្បាប់។ ខ្ញុំ រក្សាទុកច្បាប់ចម្លង ហើយច្បាប់ដើមបញ្ជូនទៅថ្នាក់លើ។ កាលពីសម័យសុនសេននៅធ្វើជាមេខ្ញុំផ្ទាល់ ចំណាររបស់ខ្ញុំនៅលើសេចក្តីសារភាព ខ្ញុំតែងតែធ្វើតាមការណែនាំរបស់គាត់តាមទូរស័ព្ទ។ ធ្វើយ៉ាងនេះ ដើម្បីសំរួលដល់ការអានឯកសារដោយថ្នាក់លើ។ ក្រោយមក នៅជាមួយនួនជា ខ្ញុំមិនមានចាររទេ ពីព្រោះគាត់ដាក់បញ្ហា។ ឯកសារច្បាប់ចម្លង ខ្ញុំទុកនៅក្នុងរោងឡានរបស់ខ្ញុំ ហើយពេលរត់ទៅ ខ្ញុំមិនបានប៉ះពាល់ឯកសារទាំងនោះទេ។ ឯកសារផ្នែកខាងសួរ អាចមាននៅតាមផ្ទះមិត្តយើងដែលជាអ្នកសួរម្នាក់ៗ។ ដូច្នេះ ប្រហែលជាពួកអ្នកទាំងនោះមិនបានកំទេចឯកសារទាំងនោះទេ។ ឯកសារបញ្ជីដែលស២១ទទួលជនរងគ្រោះ និងបញ្ចេញជនរងគ្រោះទៅដើងឯកត្រូវរក្សានៅមិត្តធីទាំងអស់។ បន្ថែមពីនេះ មានឯកសារដទៃទៀត។ តើខ្ញុំអាចនិយាយអំពីបញ្ជីកាំភ្លើងបានដែរឬទេ?

សំនួរ ML តើមានការបន្ទោសលោកទេ?

ឆ មាន គឺនៅឆ្នាំ ១៩៨៣។

សំនួរ ML តើលោកអាចប្រាប់អំពីការស្តីបន្ទោសនោះបានឬទេ?

ឆ នៅពេលដែលនួនជាគាត់ហៅខ្ញុំទៅសំណេះសំណាល ទី១ គាត់និយាយអំពីរឿងខ្ញុំទៅជួបខៀវសំផន តែមិនបានជួបគាត់។ ចំនុចនេះ ខ្ញុំបានជំរាបព្រឹកមិុញរួចហើយ។ ទី២ ក្រោយពីសួរខ្ញុំ គាត់បន្ទោសខ្ញុំថាមិត្តឯងអន់ណាស់។ ឯកសារខាងខ្ញុំ ខ្ញុំកំទេចអស់ហើយ ឯមិត្តឯងនៅទាំងកំភ្នុះ។ ទាក់ទងនឹងរឿងឯកសារ និងការបន្ទោស នៅថ្ងៃ ២៥ ខែ ៦ ១៩៨៦ សុនសេន ហៅខ្ញុំទៅមន្ទីរ ក១៨ ដែលនៅក្បែរក្រុងត្រាតខេត្តត្រាត ប្រទេសថៃ។ ពេលនោះ គាត់បញ្ជាឲខ្ញុំប្តូរឈ្មោះទៅជាពិន។ ពេលដែលជួបសុនសេន ខ្ញុំរាយការណ៍អំពីសំដីនួនជាបន្ទោសខ្ញុំ។ សុនសេន ធ្វើ ហ៊ឺះ ចាំតែអស់ចុះ នៅដូចតែគ្នាអញ្ចឹង។ រឿងនេះ សំដៅដល់ឯកសារនៅ ៨៧០។ ដូច្នោះ រឿងឯកសារ វាចប់ត្រឹមនេះឯង។

សំនួរ ML ដូច្នេះ សុនសេន មិនបានបន្ទោសលោកទេ?

ឆ សុនសេន គាត់និយាយការពិត។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

សំនួរ ML ខ្ញុំចង់ត្រឡប់មករកទំនាក់ទំនងជាមួយការជួបរបស់លោកជាមួយខៀវសំផន ដើម្បីពង្រីកបញ្ហាទាក់ទងនឹងគណៈកម្មាធិការមជ្ឈិមបក្ស។ ទំនាក់ទំនងរវាងស២១ និង មជ្ឈឹមបក្ស។ កាលពីមុនលោកបាននិយាយថាបានធ្វើរបាយការណ៍ទៅមជ្ឈិម តើ មជ្ឈិមនេះ ជាអ្វី? តើលោកជាសមាជិកគណៈកម្មាធិការមជ្ឈិមនេះដែរឬទេ? តើលោកជាប្រធានស២១ អាចគ្រប់គ្រងមន្ទីរសន្តិសុខដទៃទៀតឬទេ? តើស២១ មានទំនាក់ទំនងនឹងមន្ទីរសន្តិសុខដទៃទៀតដែរឬទេ?

ឆ គណៈកម្មាធិការមជ្ឈិមបក្ស មានច្រើនថ្នាក់។ ខ្ពស់បំផុតគឺ គណៈកម្មាធិការអចិន្ត្រៃនៃគណៈកម្មធិការមជ្ឈិមបក្ស។ មានបុគ្គល ៧នាក់ ដូចខ្ញុំរាយការជូនកាលពីលើកមុន និង ក្នុងនោះមានសមាជិកបំរុងពីរនាក់គឺ វនវេតនិងសុនសេន។ កំរិតទី២ សមាជិកមជ្ឈិមពេញសិទ្ធិ ដែលខ្ញុំមិនដឹងចំនួនទេ។ កំរិតទី៣ សមាជិកត្រៀមនៃគណៈកម្មាធិការមជ្ឈិម ដែលមានគ្នាច្រើន (ការបែងចែកគឺ សមាជិកបំរុងនៃគណៈកម្មាធិការអចិន្ត្រៃនៃគណៈកម្មាធិការមជ្ឈិមបក្ស និង សមាជិកត្រៀមនៃគណៈកម្មាធិការមជ្ឈិម)។ កំរិតទី៤ ទាបជាងគេបំផុត មានគ្នាកាន់តែច្រើន គេហៅថា ជំនួយការគណៈកម្មាធិការមជ្ឈិម។ សមាជិកមជ្ឈិម មានទាំងអស់៤កំរិត។ កុំថាតែខ្ញុំ សូម្បីតែណាត ក៏មិនមែនជាសមាជិកមជ្ឈិមដែរ។ ខ្ញុំ សុំនិយាយការទាក់ទងរបស់ខ្ញុំជាមួយនឹងថ្នាក់លើ។ ចាប់ពីថ្ងៃ ១៥ ខែ សីហា ១៩៧៥ រហូតដល់ ១៥ ខែ សីហា ១៩៧៧ ខ្ញុំទាក់ទងតែជាមួយសុនសេនទេ។ ពី ១៥ ខែ សីហា ១៩៧៧ ខ្ញុំ មានទំនាក់ទំនងតែជាមួយនួនជាទេ។ អញ្ចឹងហើយ បានជាខ្ញុំភ្ញាក់ផ្អើលណាស់ពេលជួបជាមួយខៀវសំផន នាថ្ងៃ ៦ មករា ១៩៧៩។ ចំណែកពួកដែលមន្ទីរ ៨៧០ ប្រើឲទៅទាក់ទងនិងត្រួតពិនិត្យស២១ មាន២នាក់ គឺ ឈិម សំអោក ហៅ ប៉ង់ និង មិត្ត លឹន។

សំនួរ ML តើពេលជួបខៀវសំផន តើលោកវិភាគវត្តមានរបស់ខៀវសំផនយ៉ាងដូចម្តេច? ហេតុអីគាត់បង្ហាញមុខនាពេលនោះ?

ឆ រឿងដែលខ្ញុំភ្ញាក់ផ្អើល ព្រោះគ្មានអ្នកណាឧទ្ទេសនាមឲខ្ញុំធ្វើការជាមួយគាត់ទេ។ បើយកល្អ គឺនួនជាបានឧទ្ទេសនាមជាមុនឲហើយ។ និយាយចំនុចនេះ វាធ្វើឲខ្ញុំនឹកឃើញដល់វនវេត។ វនវេត គាត់មកមុននឹងចាប់ផ្តើមនិយាយរឿងអី គាត់ឧទ្ទេសនាមសិន ថាបងនួនប្រើឲខ្ញុំមក។ ចំណែកខៀវសំផនវិញ គាត់មិននិយាយមួយម៉ាត់ជាមួយខ្ញុំផង។ គាត់និយាយតែការងារតែម្តង។

សំនួរ ML លោកនិយាយថាចុងក្រោយលោកទទួលយកបញ្ហាទៅផ្សព្វផ្សាយដល់បុគ្គលិកនៅស២១។ ដូច្នេះ ទោះបីជាមិនមានការគោរពបែបបទ ឬរបៀបដោយខៀវសំផនក៏ដោយ លោកនៅតែទទួលយកបញ្ហានោះទៅអនុវត្ត។ ហេតុអី ?

ឆ ទី១ ខ្ញុំនិយាយរួចហើយ ខ្ញុំគិតថាមិត្តលឹន មិនប៉ានធ្វើផ្តេសផ្តាស់ទេ។ ទី២ កម្មាភិបាលទាំងអស់ដែលខៀវសំផនហៅមកជួប សុទ្ធតែយកសេចក្តីណែនាំនេះទៅផ្សព្វផ្សាយនៅកន្លែងពួកគេដែរ។ ទី ៣ សេចក្តីណែនាំ

នេះ មិនទាក់ទងជាចំពោះដល់ការងាររបស់ស២១ទេ។ វា ទាក់ទងរួមដល់សភាពការយោធា។ ចុងក្រោយបំផុត ហេតុផល១ទៀតគឺប៉ុលពតផ្សាយតាមវិទ្យុថា យួនអាចចូលបានជ្រៅក្នុងប្រទេសមែន ប៉ុន្តែ សភាពការណ៍អាចត្រឡប់ក្រោយ សូមមិត្តទាំងជិតទាំងឆ្ងាយ បន្តគាំទ្រកម្ពុជាប្រជាធិបតេយ្យតទៅទៀត។ នេះ ជាមូលហេតុដែលខ្ញុំសុខចិត្តផ្សព្វផ្សាយបទបញ្ហានេះ។ ហើយក៏គ្មានផ្លូវទាក់ទងនឹងនួនជាដែរ។

សំនួរ ML នួនជាបានបន្ទោសលោក ក្រោយមកនាឆ្នាំ ១៩៨៣?

ឆ គាត់បានបន្ទោសខ្ញុំដោយបំពាន។

សំនួរ ML វាដូចជាចំឡែកដែលនួនជាបែរជាបន្ទោសលោកថាធ្វើការជាមួយខៀវសំផនតែមិនធ្វើការជាមួយគាត់ ទាក់ទងនឹងការងារមួយដែលគ្រាន់តែជាការអំពាវនាវឲទប់ទល់តែប៉ុណ្ណោះ។ តើវាមានភាពតានតឹងរវាងនួនជា និងខៀវសំផនដែរឬទេ?

ឆ ខ្លឹមសាររបស់ខៀវសំផន គឺឲស២១ និងអង្គភាពដទៃទៀតរក្សារភាពស្ងប់ស្ងាត់ កុំភ្ញាក់ផ្អើល។ ទី ១ មិនមានការសុំឲតទល់នឹងកំលាំងដែលចូលមកទេ៕ ទី២ តាមពិតទៅ នួនជា គួរតែនិយាយពន្យល់ខ្ញុំឲខ្ញុំអស់ចិត្តអំពីការដែលគាត់មិនបានប្រាប់ខ្ញុំឲរត់ដូចគេ។ ប៉ុន្តែ គាត់បែរជាបន្ទោសខ្ញុំទាំងបំពានទៅវិញ។ទម្លាប់ធ្វើការរបស់នួនជាគឺអញ្ចឹង៕ គាត់បន្ទោសគេដោយបំពាន។ ប្អូនថ្លៃគាត់ ឈ្មោះ កួយ ទទួលបន្ទុកស្ថានីយវិទ្យុស្ទឹងមានជ័យត្រូវបានស្តីបន្ទោសខ្លាំងជាងខ្ញុំទៅទៀត។ កួយឯងគិតតែពីដើរលេង ឲគេទៅប្រាប់រកមិនឃើញ។

អស ជា លាង សួរសំនួរ: កាលពីព្រឹកម៉ិញលោកថាចេញពីភ្នំពេញ នៅថ្ងៃ៧ មករា ១៩៧៩ ម៉ោង ១១ ព្រឹក។ តើមុនចេញទៅ តើអ្នកបានឃើញជនរងគ្រោះនៅស២១ដែលនៅរស់ តើគេកំពុងធ្វើអ្វី? តើជនរងគ្រោះមានសភាពដូចម្តេចមុនការចាកចេញរបស់អ្នកឯង?

សំនួរ ML បើខ្ញុំចាំ កាលពីព្រឹកម៉ិញ លោកថាមានជនរងគ្រោះ ២០០ នាក់ ហើយ ត្រូវបានសម្លាប់អស់ហើយ?

ឆ បញ្ហាមាន ២។ ទី១ អ្នកទោសប្រហែល១០នាក់ដែលទុកឲបំពេញការងារនៅស២១ ដើម្បីរង់ចាំការអនុគ្រោះទោសជាយថាហេតុ។ ពួកនេះ ខ្ញុំក្តាប់អត់បានទេ មិនដឹងយ៉ាងម៉េចទេ។ ដោយឡែក ពួក យ៨ ដែលទើបនឹងបញ្ជូនទៅស២១ នួនជា អនុញ្ញាតឲខ្ញុំទុកឲគេសួរសិន។ សុំបញ្ជាក់បន្តិច។ ពួក យ៨ នេះ មាន១ នាក់ ឬ ២ នាក់ ជាអ្នកបាញ់អ្នកកាសែតអង់គ្លេស ឈ្មោះ Richard Edmond។ [Dudman??] តែនួនជា ផ្តាំផ្តាច់ថាបើមានការអីឲម្ចាស់ការខ្លួនឯង។ នៅពេលដែលកងទ័ពចូលមកដល់ ហើយ អ្នកទាំងអស់ឆ្ពោ ខ្ញុំនឹកអត់ឃើញទេ។ ដល់ទៅវត្តសន្សំកុសល ទើបខ្ញុំដេញដោលសួរគេ គេប្រាប់ខ្ញុំថាមិត្ត ណាន ជាអ្នកសួរម្នាក់ បានកំទេចទាំង៤ ហើយដោយប្រើ Bayyonnette។ គឺទាហានទាំង៤នាក់ ដែលបញ្ជូនដោយពួក យ៨។ អ្នកទោសស្ទើរតែទាំងអស់ត្រូវបានសម្លាប់ នៅថ្ងៃទី២ ឬ ៣ មករា លើកលែងតែអ្នកទាំង៤នាក់នេះចេញ៕ តែ ពួកគេទាំង៤ ត្រូវសម្លាប់ដោយណាន នៅថ្ងៃ៧ មករា។ គឺសពពួកនេះហើយដែលនៅសល់ឃើញគ្រែ មិនមាននរណាយកទៅកប់ទេ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

សំនួរ អស ជាលាង: តើតាំងពីថ្ងៃ ២ ឬ ៣ មករា ១៩៧៩ ក្រោយពេលទទួលបញ្ជាពីនួនជា តើ ហ៊ី បានអនុវត្តតាមបញ្ជាចាប់ពីពេលនោះតើយ៉ាងណា?

ឆ ច្បាស់លាស់ណាស់។ គឺគេបានអនុវត្តភ្លាម។ ដល់រួចរាល់ហើយ គេមកប្រាប់ខ្ញុំថាចប់សព្វគ្រប់អស់ហើយ។

សំនួរ Alex Bates តើពិតទេ ថាលោកបានជួបអ្នកកាសែត Neit Thayer?

ឆ ពិត។

សំនួរ Alex Bates នៅ ១៩៩៩? ហើយលោកនិយាយអំពីចំនុចជាច្រើន។ ទាក់ទងនឹងអ្នកទោសដែលត្រូវបានសម្លាប់នៅខែមករា១៩៧៩ លោកនៅចាំទេថាលោកបានប្រាប់គាត់ថាលោកបានសម្លាប់អ្នកទោស។

លោកមេធាវី Francois Roux: លោកចៅក្រម ខ្ញុំសូមឲការឆ្លើយសំនួរនេះត្រូវធ្វើនៅពេលណាដែលខាងមេធាវីការពារអាចទទួលបានសំណុំរឿងចម្លងមួយច្បាប់។ សហព្រះរាជអាជ្ញាបានដឹងអំពីសំណុំរឿងនេះយូរមកហើយ។ ឯខាងយើង មិនទាន់បានទទួលសំណុំរឿងចម្លងមួយច្បាប់។ ដូច្នេះវាជាអតុល្យភាពមួយរវាងយើងទាំងពីរ។ កាលពីរសៀលនេះ យើងបានដាក់ពាក្យសុំពិនិត្យច្បាប់ចម្លងសំណុំរឿងទាំងមូល លើកលែងតែផ្នែកខ្លះ។

សំនួរ ML ចំពោះ ជនត្រូវចោទ តើលោកគិតយ៉ាងម៉េចដែរទាក់ទងនឹងសំនួរនេះ ?

ឆ ខ្ញុំសុំមិនទាន់ឆ្លើយទេ។

អស ជាលាង បានកត់សំគាល់ថា នេះជាចំនុចមិនទាក់ទងគ្នាទេការដែលលើកឡើងដោយលោកមេធាវីទាក់ទងនឹងការសិក្សាសំណុំរឿង។ ប៉ុន្តែ ជនត្រូវចោទ មានសិទ្ធិឆ្លើយឬមិនឆ្លើយ នេះជាសិទ្ធិរបស់គាត់។។

សំនួរ ML ពីព្រឹកមិុញ លោកថាលោកមិនដែលសម្លាប់នរណាម្នាក់ទេ តើលោកនៅតែប្រកាន់ជំហរនេះ?

ឆ បាទ ខ្ញុំយកជំហរដែលខ្ញុំបាននិយាយប្រាប់លោកចៅក្រម។

☒ យើងបានអញ្ជើញ មេធាវីជនត្រូវចោទ និងជូនដំណឹងជនត្រូវចោទ និង សហព្រះរាជអាជ្ញាអំពីការសួរចម្លើយលើកក្រោយដែលមានកាលបរិច្ឆេទថ្ងៃទី ០៥ កញ្ញា ២០០៧ ម៉ោង ៩ ព្រឹក ទីកន្លែងដដែល។

☒ ឯកសារច្បាប់ដើមនៃការថតរូបភាពនិងសម្លេង ត្រូវបានបិទស្លាកបោះត្រានៅចំពោះមុខជនត្រូវចោទនេះ និងមេធាវីរបស់ជននេះ និង ត្រូវបានចុះហត្ថលេខាដោយ យើង ក្រឡាបញ្ជី ជនត្រូវចោទ និង មេធាវីរបស់ជននេះ។

☒ ឯកសារច្បាប់ដើមមួយច្បាប់នៃការថតរូបភាពនិងសម្លេង ត្រូវបានប្រគល់ឲ្យជនត្រូវចោទនេះ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

00146561

~~ឯកសារលេខ: D13/1~~
E3/25

នៅវេលាម៉ោងប្រាំនិងម្ភៃបួននាទី ល្ងាច យើងបានឲ្យក្រឡាបញ្ជីអានខ្លាំងៗនូវកំណត់ហេតុស្តួរចម្លើយរបស់ជនត្រូវចោទនេះ ទៅតាមអ្វីដែលបានកត់ត្រា។

☒ អានឲ្យស្តាប់ហើយ ជនត្រូវចោទ មិនមានជំទាស់អ្វីទេ ហើយ សុខចិត្តចុះហត្ថលេខា។

| ជនត្រូវចោទ | មេធាវីជនត្រូវចោទ | សហព្រះរាជអាជ្ញា | អ្នកបកប្រែ | ក្រឡាបញ្ជី | សហចៅក្រមស៊ើបអង្កេត |
|---|---|---|---|---|---|
| Charged person<br>Personne mise en examen | Lawyer of Charged person<br>Avocat de la Personne mise en examen | C0-Prosecutors<br>Co-procureurs | Interpreter<br>Interprète | Greffiers | Co- Investigating Judges<br>Co-juges d'instruction |



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.